**បាឋកថាស្តីអំពី**

**«ការបង្រៀនអំពីហូឡូខសត៍ (Holocaust) នៅប្រទេសអាឡឺម៉ង់៖ បញ្ហាប្រឈមនៃការប្រឈមមុខនឹងអតីតកាលអស់រយៈពេលជាង៧០ឆ្នាំកន្លងមក»**

ដោយ Anne Hennings

**ថ្ងៃអង្គារ ទី៣១ ខែមករា ឆ្នាំ២០១៧ វេលាម៉ោង ៤:០០ រសៀល**

ទីតាំង៖ វិចិត្រសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

អគារ H វិទ្យាស្ថានជាតិអប់រំ

ភាសា៖ អង់គ្លេស និងប្រែសម្រួលជាភាសាខ្មែរ

វិចិត្រសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សូមជូនដំណឹងថា វិចិត្រសាលនឹងរៀបចំ បាឋកថាទីដប់ប្រាំបួន ស្តីអំពី **«ការបង្រៀនអំពីហូឡូខសត៍ (Holocaust) នៅប្រទេសអាឡឺម៉ង់៖ បញ្ហាប្រឈមនៃការប្រឈមមុខនឹងអតីតកាលអស់រយៈពេលជាង៧០ឆ្នាំកន្លងមក»** ដោយ Anne Hennings ។ សិស្ស និស្សិត គរុសិស្ស និងសាធារណជន អាចចូលរួម ដោយសេរី។

ការកើនឡើងនៃការវាយប្រហាទៅលើផ្ទះសម្បែងរបស់ជនភៀសខ្លួន ការរើសអើងពូជសាសន៍ ការរើសអើងទៅលើជនជាតិជ្វីប និងការកើនឡើងនៃប្រជាប្រិយភាពរបស់ជនស្តាំនិយម ដែលកើតមាននៅពេលថ្មីៗនៅប្រទេសអាល្លឺម៉ង់ និងអឺរ៉ុប បានរម្លឹកនូវការចងចាំដ៏អាក្រក់ និងបានឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃការសិក្សាពីអតីតកាល។ ក្រៅអំពីយុត្តិធម៌ និងការពិតដែលមានសារៈសំខាន់ក្នុងការយល់ដឹងអំពីជម្លោះបែបហិង្សានិងឧក្រិដ្ឋកម្មសង្គ្រាម ផ្នត់គំនិត និងឥរិយាបថមិនអាចនឹងផ្លាស់ប្តូរបានភ្លាមៗនោះទេ។ នេះគឺដំណើរការមួយដ៏វែង។ ការបង្រៀនអំពីអតីតកាលគឺជាវិធីមួយ ដើម្បីជម្រុញឲ្យមានការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថ។ ហេតុដូច្នេះ ការសិក្សាអំពី ហូឡូខសត៍ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅប្រទេសអាល្លឺម៉ង់ រួមមានការធ្វើទស្សនកិច្ចសិក្សាទៅកាន់បូជនីយដ្ឋាន ជំរំលត់ដំ សារមន្ទីរ និងការជជែកពិភាក្សាជាមួយអ្នករស់រានមានជីវិត។ បើទោះបីជាការអប់រំផ្នែកនយោបាយមិនអាចជៀសផុតពីការបង្រៀនអំពីការកើតឡើងនៃរបបណាហ្ស៊ី-អាល្លឺម៉ង់ និងហូឡូខសត៍ បញ្ហាប្រឈមមួយចំនួននៅតែកើតមាន។ ទីមួយ បើទោះបីជាអស់រយៈពេលជាច្រើនឆ្នាំកន្លងផុតទៅហើយក៏ដោយ ក៏ការនិយាយអំពីការពិតនៅតែបង្កឲ្យមានការប៉ះទង្គិចផ្នែកផ្លូវចិត្ត ជាពិសេសគឺការមានអារម្មណ៍ខុសឆ្គង និងការខ្មាស់អៀន។ មតិរិះគន់មួយចំនួនបានលើកឡើងអំពីការដាក់សម្ពាធទៅលើក្មេងជំនាន់ក្រោយ។ ទីពីរ មតិមួយចំនួនផ្សេងទៀតបានលើកឡើងថា បើទោះបីជា ការសិក្សាអំពីហូឡូខសត៍មានសារៈសំខាន់ ប៉ុន្តែការបង្រៀននោះហាក់ដូចជាត្រូវបានបង្រៀនច្រើនពេក ដែលអាចបង្កឲ្យភាពព្រងើយកន្តើយនៅក្នុងចំណោមសិស្សានុសិស្ស។ ម្យ៉ាងវិញទៀត ការប្រឈមមុខនឹងប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់ប្រទេសអាល្លឺម៉ង់ តែងតែមានការជជែកពិភាក្សារវាងក្មេងជំនាន់ក្រោយ និងអ្នករស់រានមានជីវិត។ ហេតុដូច្នេះការពិភាក្សានេះអាចបង្កឲ្យមានការប៉ះទង្គិចផ្លូវចិត្តទៅដល់ក្មេងជំនាន់ក្រោយដោយមិនដឹងខ្លួន។ ជាសរុប បើទោះបីជាមានបញ្ហាប្រឈមមួយចំនួនក៏ដោយ ក៏ការសិក្សាអំពីហូឡូខសត៍នៅតែមានសារៈសំខាន់ក្នុងការទប់ស្កាត់ "មិនឲ្យកើតឡើងម្តងទៀត" ការរើសអើងជាតិសាសន៍ និងការរើសអើងជនជាតិជ្វីប។

Anne Hennings គឺជាអ្នកស្រាវជ្រាវមួយរូបនៅក្នុងមូលនិធិ Heinrich Boell នៅទីក្រុងភ្នំពេញ និងជាបេក្ខជនបណ្ឌិតនៅសាកលវិទ្យាល័យ Muenster ប្រទេសអាល្លឺម៉ង់។ ការស្រាវជ្រាវរបស់គាត់ផ្តោតទៅលើ សង្គមក្រោយជម្លោះនៅតំបន់អាស៊ីអាគ្នេយ៍និងអាហ្វ្រិក ដែលទាក់ទងទៅនឹងធនធានធម្មជាតិ អតីតយុទ្ធជន និងការផ្លាស់ប្តូរនៃជម្លោះ។ Anne ក៏ជាវាគ្មិន និងជាសហស្ថាបនិកនៃក្រុមស្រាវជ្រាវមួយដែលសិក្សាអំពី «ធម្មជាតិ-ធនធាន-ជម្លោះ»។

### សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

ការចងចាំ និងយុត្តិធម៌
«…សង្គមមួយមិនអាចស្គាល់ខ្លួនឯងបាន ប្រសិនបើសង្គមនោះមិនមានការចងចាំដ៏ត្រឹមត្រូវអំពីប្រវត្តិសាស្ត្ររបស់ខ្លួន។»
ម៉ែន ពិចិត្រ
វិចិត្រសាលសិល្បៈសហសម័យ
មជ្ឈមណ្ឌលឯកសារកម្ពុជា
ទូរសព្ទ +៨៥៥ ២៣ ២១៤ ០០៩
អ៊ីម៉ែល truthmpechet@dccam.org
គេហទំព័រ www.dccam.org